AGING AND LONG TERM SUPPORT ADMINISTRATION
PO BOX 45600
OLYMPIA WA 98504-5600

# សិទ្ធិរបស់អ្នក

## Your Rights

អ្នកមានសិទ្ធិក្នុងការមានសេរីភាពរួចផុតពីការត្រូវគេបោះបង់, រំលោភបំពាន, គេប្រវ័ញ្ចប្រាក់កាស, និងធ្វេសប្រហែស។ បើអ្នកមានមូល ហេតុគួរឲ្យជឿថា អ្នកកំពុងពើបប្រទះនឹងការត្រូវគេបោះបង់, រំលោភបំពាន, គេប្រវ័ញ្ចប្រាក់កាស, ឬធ្វេសប្រហែស, នោះអ្នកមានសិទ្ធិ ៖

1. រាយការណ៍ប្រាប់ទៅ**ក្រសួងសេវាសង្គមកិច្ចនិងសុខាភិបាល** (Department of Social and Health Services, DSHS) និងភ្នាក់ងារមានសមត្ថកិច្ច ព្រមទាំងចែករំលែកព័ត៌មានដែលអ្នកជឿថា អាចមានការពាក់ព័ន្ធដល់ការស៊ើបអង្កេត និងស្វែងរកជន ណាម្នាក់ដែលអ្នកជឿថា អាចមានព័ត៌មានដែលពាក់ព័ន្ធករណីទាំងនោះ។
2. មានសេរីភាពរួចផុតពីការសងសឹកសម្រាប់ការផ្តល់សេចក្តីរាយការណ៍ ឬការបណ្តាលឲ្យមានសេចក្តីរាយការណ៍អំពីបទត្រូវគេ បោះបង់, រំលោភបំពាន, គេប្រវ័ញ្ចប្រាក់កាស, ឬធ្វេសប្រហែស។
3. ទទួលបាននូវការរាប់អានដោយសេចក្តីគោរពថ្លៃថ្នូរ និងការពោលពាក្យប្រស្រ័យទាក់ទងដោយភាសាពីរោះប្រសើរ។
4. ទទួលបានការសម្របសម្រួលដោយសមរម្យសម្រាប់ពិការភាពរបស់អ្នក នៅក្នុងពេលធ្វើសេចក្តីរាយការណ៍, និងក្នុងអំឡុងពេលធ្វើ ការស៊ើបអង្កេត និងនីតិវិធីរដ្ឋបាល។
5. ស្នើសុំដីកា ដើម្បីហាមឃាត់ជនណាម្នាក់ ដែលបានបោះបង់, រំលោភបំពាន់, គេប្រវ័ញ្ចប្រាក់កាស, ឬធ្វេសប្រហែសមិនថែរក្សាអ្នក ដើម្បីកុំឲ្យជនរូបនោះ ស្ថិតក្បែរ ឬស្នាក់នៅក្នុងបរិវេណផ្ទះសំបែងរបស់អ្នក, ធ្វើការប្រស្រ័យទាក់ទងជាមួយអ្នក, ឬប្រើប្រាក់កាស ឬទ្រព្យសម្បត្តិរបស់អ្នក។
6. ទទួលបានព័ត៌មានពីក្រសួង DSHS និងការបញ្ជូនដោយសមរម្យទៅកាន់ទីភ្នាក់ងារដទៃៗ ដែលអាចជួយគាំពារ, ស៊ើបអង្កេត, ឬ ចាត់វិធានការផ្លូវច្បាប់ផ្សេងៗ។
7. ទទួលបាននូវការផ្តល់ព័ត៌មានស្តីអំពីស្ថានភាពនៃការស៊ើបអង្កេត, ការប្រតិបត្តិនីតិវិធី, ការប្រតិបត្តិចំណាត់ការតុលាការ, និងលទ្ធផល ផ្សេងៗ ដែលបានធ្វើឡើងដោយទីភ្នាក់ងារ ដែលកាន់កាប់សំណុំរឿងណាមួយ ដែលពាក់ព័ន្ធនឹងរូបអ្នក ដែលជាជនរងគ្រោះ។
8. ស្នើសុំឲ្យគេបញ្ជូនទៅកាន់ទីភ្នាក់ងារគាំពារ ឬទីភ្នាក់ងារជំនួយផ្នែកច្បាប់ ដើម្បីជួយរូបអ្នក ក្នុងការរៀបចំបង្កើតផែនការសុវត្ថិភាព, ផែនការស៊ើបអង្កេត, និងផែនការសវនាការ។
9. ដាក់បណ្តឹងតវ៉ាទៅក្រសួង DSHS ជាផ្លូវការឬមិនផ្លូវការ, ស្តីអំពីការស៊ើបអង្កេត ឬការធ្វើនីតិវិធី, ហើយទទួលបានការឆ្លើយតប ដោយសមរម្យ និងទាន់ពេលវេលា។

**ដើម្បីរាយការណ៍អំពីអំពើរំលោភបំពាន, បោះបង់ចោល, ធ្វេសប្រហែស, ធ្វេសប្រហែសដោយសាមីខ្លួន ឬគេប្រវ័ញ្ចប្រាក់កាស, ឬដើម្បី ស្នើសុំព័ត៌មានផ្សេងៗ, សូមអញ្ជើញទូរស័ព្ទទាក់ទង ៖**

**1-866-EndHarm (1-866-363-4276)**

**សម្លេង/ប្រព័ន្ធ TTY 1-800-737-7931**

អ្នកនឹងត្រូវបានផ្ទេរ ទៅកាន់ការិយាល័យទទួលអតិថិជន APS (APS Intake Office) ប្រចាំមូលដ្ឋានរបស់លោក អ្នក ដើម្បីធ្វើសេចក្តីរាយការណ៍ ឬស្នើសុំព័ត៌មានផ្សេងៗ។

ព័ត៌មានសម្រាប់ការប្រស្រ័យទាក់ទងក្នុងមូលដ្ឋាន ៖